# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

## ព្រះរាជក្រម នស/រកម/០៥៩៩/០៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ ហើយមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ការហាមប្រើប្រាស់គ្រាប់មីន គ្រប់ប្រភេទប្រឆាំងមនុស្ស

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .- ច្បាប់នេះ មានគោលដៅហាមឃាត់ការប្រើប្រាស់ ការផលិត ការកាន់កាប់ ការជួញដូរ ការនាំចេញ និងការនាំចូលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ។

មាត្រា ២ .- គ្រាប់មីនប្រឆាំងមនុស្ស គឺគ្រាប់មីនទាំងឡាយដែលធ្វើឡើង ដើម្បីឲ្យផ្ទុះនៅពេលមានវត្តមានមនុស្សក្នុងទីជិត ឬឆ្ងាយ ឬនៅពេលមនុស្សទៅប៉ះបណ្តាលឲ្យមនុស្សម្នាក់ ឬច្រើននាក់ រងរបួស ពិការ ឬស្លាប់ ។

គ្រាប់មីន គឺជាយុទ្ធោបករណ៍ ដែលគេយកទៅកប់ក្នុងដី ឬដាក់លើផ្ទៃដី ឬនៅលើទីដទៃទៀត ហើយដែលផ្ទុះនៅពេលមានវត្តមានឆ្ងាយ ឬជិតនៃមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទាំងឡាយ ឬផ្ទុះនៅពេលមានមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទៅប៉ះ ។

មាត្រា ៣ .- ជនស៊ីវិល ភ្នាក់ងាររាជការទាំងអស់ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាពិសេសកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងកំលាំងនគរបាលជាតិ ត្រូវហាមឃាត់ប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សក្នុងគ្រប់កាលៈទេសៈ លើកលែងតែក្នុងករណីប្រើប្រាស់ដើម្បីធ្វើការបណ្តុះបណ្តាលរឿងហាត់បោសសំអាតមីន ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

មាត្រា ៤ .- ការត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ជាសមត្ថកិច្ចរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

មាត្រា ៥ .- ក្រៅពីភារកិច្ច ដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ភារកិច្ចបន្ថែមរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាមាន ៖

- ចូលរួមសហការធ្វើអធិការកិច្ចជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធនៅគ្រប់ទីកន្លែង ដែលគេសង្ស័យថាមានការរំលោភលើការហាមឃាត់ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

- សំអេចក៏ទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សទាំងអស់ ដែលនៅមាន និងរកឃើញ ។
- សំអេចក៏ទេចចោលគ្រាប់មីនគ្រប់ប្រភេទក្រៅពីគ្រាប់មីនប្រឆាំងមនុស្ស និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់ ដែលនៅមាន និងរកឃើញដោយពុំមានការគ្រប់គ្រង និងថែរក្សាទុកឲ្យអាជ្ញាធរមានសមត្ថកិច្ច ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការបរទេស ដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ។
- ទទួលរបាយការណ៍ពីអង្គភាពនានា ស្តីពីការប្រើប្រាស់ដោយគិតទាំងការកាន់កាប់ ការផ្ទេរ ការផ្តល់ ការនាំចេញ ការនាំចូលគ្រាប់មីនគ្រប់ប្រភេទ ហើយរាយការណ៍ជូនរដ្ឋាភិបាល ។
- ទទួលភារកិច្ចធ្វើការគ្រប់គ្រង ត្រួតពិនិត្យ ឬសំរបសំរួលការងារដោះមីន និងកំទេចគ្រឿងផ្ទុះគ្រប់ប្រភេទ នៃអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ដែលកំពុង ឬដែលនឹងមកបំពេញកិច្ចប្រតិបត្តិការបោសសំអាតមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ធ្វើសហការជាមួយស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតូបករណ៍អន្តរជាតិទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងបញ្ហាមីនប្រឆាំងមនុស្សគ្រប់ប្រភេទ ។

ក្រសួង ឬ ស្ថាប័នដែលត្រូវចូលរួមធ្វើអធិការកិច្ចនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

មាត្រា ៦ .- ជនណាកាន់កាប់ ថែរក្សាទុក ដោយចេតនានូវគ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំ និងពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

មាត្រា ៧ .- ជនណាប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ដោយមិនទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរចំពោះបច្ច័យនៃបទល្មើស ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិត និងរូបរាងកាយមនុស្ស និងសំណង់រដ្ឋប្បវេណីផ្សេងៗទៀតឡើយ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

មាត្រា ៨ .- ជនណាផលិត ជួញដូរ នាំចូល ឬនាំចេញ គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរប្រាំឆ្នាំ ដល់ដប់ឆ្នាំ និងពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ម្ភៃលាន (២០.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

គ្រាប់មីនទាំងឡាយ ដែលបានលើកឡើងក្នុងមាត្រា៦ មាត្រា៧ និងមាត្រា៨ ត្រូវរឹបអូស និងបំផ្លាញចោល ។

មាត្រា ៩ .- បើជនល្មើសជាភ្នាក់ងារ ឬមន្ត្រីនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ឬជាមន្ត្រី នៃអង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសកម្មភាពប្រហាក់ប្រហែលនឹងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាដែរនោះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៦ មាត្រា៧ និងមាត្រា៨ នៃច្បាប់នេះជាអតិបរមា ដោយឥតមានការសំរាលទោសឡើយ ។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

មាត្រា ១០.- ជនណា ឬក្រសួងណា ឬស្ថាប័នណាដែលបានកាន់កាប់គ្រាប់មីនប្រឆាំងមនុស្សប្រភេទណាក៏ដោយ ត្រូវធ្វើរបាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលមានកាតព្វកិច្ចធ្វើសេចក្តីរាយការណ៍ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បញ្ជាក់អំពីប្រភេទ ចំនួន និងព័តមានពិស្តារផ្សេងៗពាក់ព័ន្ធនឹងគ្រាប់មីន ដែលខ្លួនកំពុងកាន់កាប់ ថែរក្សាទុកក្នុងរយៈពេលកៅសិបថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលច្បាប់នេះ ចូលជាធរមានប្បញ្ញត្តិ ។

មាត្រា ១១.- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ត្រូវកំចាត់គ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទទាំងនោះ តាមការកំណត់ដូចមានចែងក្នុងមាត្រា១០ ឲ្យអស់ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រួចហើយត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១២.- បទប្បញ្ញត្តិទាំងឡាយណា ដែលពាក់ព័ន្ធនឹងបញ្ហាមីនប្រឆាំងមនុស្ស ហើយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សុខ អាន

★★★

# ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៥/៣៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**លោកអាចារ្យ ហេង គឹមគុណ**

**ជា**

**អ្នកឧកញ៉ា ឧត្តលកិច្ចការធម្មការក្នុងព្រះបរមរាជវាំង**

ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★